# អក្សរសិល្ប៍ខ្មែរ

# ក្នុងវេលាកាល នវរាជានិយម

(The Cambodian Literature during the Neoroyalist Period )

by KHING Hoc Dy

ដោយ បណ្ឌិត **ឃីង ហុក ឌី**

អក្សរសិល្ប៍វិទូ នៅមជ្ឈមណ្ឌលជាតិ ស្រាវជ្រាវវិទ្យាសាស្ត្រ ក្រុងប៉ារីស សាស្ត្រាចារ្យ អក្សរសិល្ប៍ខ្មែរនៅ វិជ្ជាស្ថានជាតិ ភាសា និងអរិយធម៌ បូព៌ា ប្រទេស ក្រុងប៉ារីស

*អក្សរសិល្ប៍ ចាប់តាំងពីពាក់កណ្ដាល សតវត្ស ទី ២០មក បាន ទទួលការវិវត្តន៍ ជាច្រើនលើក ច្រើនគ្រា ដោយទាក់ទងយ៉ាងជិតស្និទ្ធ ទៅនឹងស្ថានភាពប្រទេស ក្នុងវិស័យនយោបាយ សេដ្ឋកិច្ច សង្គមបរិយាកាស និងប្រព័ន្ធវប្បធម៌នានា ។ ការផ្លាស់ប្ដូរនយោបាយ សេដ្ឋកិច្ច សង្គម ជាញឹកញាប់ ធ្វើអោយអក្សរសិល្ប៍ ខំវិវត្តន៍ ទៅតាមបង្វាក់វណ្ណៈអ្នកដឹកនាំ ។ ក្នុងដំណាក់កាល នយោបាយនីមួយៗ រដ្ឋអំណាច បានផ្លាស់ប្ដូររដ្ឋធម្មនុញ្ញ ដោយចារបទចម្រៀងជាតិ អោយស្របនឹងបន្ទាត់មនោគមវិជ្ជា ក្នុងសម័យនានា ។ បន្ទាប់ ពី ការព្រមព្រៀង រវាង រដ្ឋាភិបាល រដ្ឋ កម្ពុជា ( អតីត សាធារណរដ្ឋ ប្រជាមានិត កម្ពុជា ដែលមាននិន្នាការ ជាប់នឹងហាណូយ) បានចុះហត្ថលេខា នៅ ថ្ងៃ២៣តុលា១៩៩១ នៅទីក្រុងប៉ារីស ក្រោមអធិបតីភាព នៃអង្គការ សហប្រជាជាតិ ។ ការបោះឆ្នោត ជាសកល បានធ្វើឡើង នៅ ខែឧសភា ១៩៩៣ តែគ្មាន ការ ចូលរួមចំណែក ពី ខ្មែរ ក្រហម ( កម្ពុជាប្រជាធិបតេយ្យ)។ សភាជាតិ បាន បដិសន្ធិឡើង ហើយ រដ្ឋធម្មនុញ្ញថ្មី ត្រូវបាន សភាអនុម័ត នៅ ភ្នំពេញ ថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ១៩៩៣ នាសម័យ ប្រជុំពេញអង្គ លើកទី២ ហើយ បាន ទទួល ព្រះហត្ថលេខា ពី* សម្ដេច ព្រះបាទ**នរោត្តម សីហនុ** *នៅ ថ្ងៃ២៤ កញ្ញា១៩៩៣ ។ ក្នុង មាត្រា ១ នៃ រដ្ឋ ធម្មនុញ្ញ បញ្ជាក់ថា៖* << ប្រទេស កម្ពុជា ជាព្រះរាជាណាចក្រ ដែល ព្រះ មហាក្សត្រ ទ្រង់ប្រតិបត្តតាមរដ្ឋធម្មនុញ្ញនិងតាមលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស>>។ *ក្នុងមាត្រា៥ ចារថា៖* << ភាសានិង អក្សរ ដែល ប្រើ ជា ផ្លូវការ គឺ ភាសា និង អក្សរ ខ្មែរ >> *ហើយ ក្នុង មាត្រា ៧ ចែងថា ៖* << ព្រះមហាក្សត្រ កម្ពុជា ទ្រង់គ្រង រាជសម្បត្តិ ប៉ុន្តែ ទ្រង់មិន កាន់អំណាច ឡើយ >> ។ *ប្រទេស កម្ពុជា បានត្រឡប់ ទៅ ជា*

ព្រះរាជាណាចក្រ កម្ពុជា វិញដោយ មាន សម្តេច ព្រះបាទនរោត្តម សីហនុវរ្ម័ន ឡើងសោយរាជជាលើកទី២ ។ ព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយនាយករដ្ឋមន្ត្រី២រូប គឺ សម្តេចក្រុមព្រះ នរោត្តម រាណឫទ្ធិ និងសម្តេច ហ៊ុនសែន ហើយក្រសួងនិមួយៗ មានរដ្ឋមន្ត្រី២រូប គឺមួយជាសមាជិក គណៈបក្ស ហ៊្វុនស៊ិនប៉ិច និងមួយទៀតជាសមាជិក គណៈបក្ស ប្រជាជនកម្ពុជា ( អតីតគណៈកុម្មុយនិស្តខ្មែរ) ។ បន្ទាប់ពី រដ្ឋប្រហារ ដោយនាយករដ្ឋមន្ត្រីទី២ **ហ៊ុនសែន** នៅខែកក្កដា ១៩៩៧ បានធ្វើអោយរដ្ឋមានផលវិបាកផ្នែកសេដ្ឋកិច្ចយ៉ាងខ្លាំង អាស្រ័យដោយប្រទេសជាអ្នកផ្តល់ជំនួយ នានាផ្តាច់ ឬផ្អាកជំនួយមួយគ្រាសិន ។ ដោយការរិតរួត អន្តរជាតិផ្នែកសេដ្ឋកិច្ច និងនយោបាយយ៉ាងនេះ បានធ្វើអោយសមាជិក ហ៊្វុនស៊ិនប៉ិច ដែលភៀសខ្លួននៅប្រទេសថៃ និងបរទេស ព្រមទាំងសមាជិក សមរង្ស៊ី មានលទ្ធភាពត្រឡប់មកភ្នំពេញវិញ ដើម្បីចូលរួមក្នុងការបោះឆ្នោតសភា នៅថ្ងៃ២៦ កក្កដា ១៩៩៨ ។ ចំនួនតំណាងរាស្ត្រទាំងអស់មាន១២២រូប ។ ចំណែកអំណាចនិតិបញ្ញត្តិ មាន សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុនសែន** និងរដ្ឋមន្ត្រី ក្នុងក្រសួងនិមួយៗ អមដោយ រដ្ឋលេខាធិការ ២ រូប ព្រមទាំង មានជំនួយ ដោយអនុរដ្ឋលេខា៤រូបទៀត ។ រួមសេចក្តីមកគឺមានទាំងអស់៤២រដ្ឋមន្ត្រីនិងរដ្ឋលេខាធិការ ហើយនិង១៣២អនុរដ្ឋលេខាធិការ ។

ទាំងនេះបានសេចក្តីថា នៅរយៈទសវត្សចុងក្រោយនៃសតវត្សទី២០ នេះឃើញមានការផ្លាស់ប្តូរនយោបាយជាច្រើនជងមកហើយ តើអក្សរសិល្ប៍ខ្មែរបានធ្វើវិវត្តន៍តាមបង្វាក់នយោបាយប្រទេស ឬយ៉ាងណា?

១) អក្សរសិល្ប៍នៅឆ្នាំ១៩៩០ ដល់១៩៩៣

ឆ្នាំ១៩៩០ គឺជាឆ្នាំដែលយើងត្រូវកត់ បារីក សំគាល់ ទុកជាសភាពការណ៍មួយសំខាន់នៃស្រុកខ្មែរ ព្រោះរដ្ឋាភិបាលនៃរដ្ឋកម្ពុជា ភ្នំពេញ និងរដ្ឋាភិបាលចំរុះ កំពុងតែរិះរកមធ្យោបាយនានា ទាំងផ្លូវទូត ទាំងផ្លូវនយោបាយ ដើម្បីធ្វើដំណើរទៅរកសន្តិភាព ។ ចាប់តាំងពីពេលនេះមក អក្សរសិល្ប៍ខ្មែរហាក់ដូចជាឋិតនឹង មួយកន្លែងចាំនូវដង្ហើមថ្មីមួយ ទៀតដើម្បីនឹងជំរុញបោះជំហានទៅមុខទៀត ។ នៅក្នុងរយៈពេលនេះ គ្រឹះស្ថានផ្លូវការនានា ដូចជា << អាគារបោះពុម្ពផ្សាយវប្បធម៌ គ្រឹះស្ថានបោះពុម្ពបដិវត្ត>> ។ល។ បានបោះពុម្ពផ្សាយឡើងវិញ នូវ អត្ថបទ អក្សរសិល្ប៍ នៅ សម័យសង្គមរាស្ត្រនិយម (១៩៥៥-១៩៧០) និងសម័យសាធារណរដ្ឋ (១៩៧០-១៩៧៥) ។ ឯចំណែកគ្រឹះស្ថានបោះពុម្ពឯកជន នានា ក៏ចាប់បដិសន្ធិឡើងដែរ ហើយបានបោះពុម្ពអត្ថបទអក្សរសិល្ប៍

នៅសម័យមុនៗ គឺក្នុងរវាងឆ្នាំ១៩៥៥-១៩៧៤ មានសិក្សាកថា ប្រលោមលោក កម្រង ចំរៀង ។ល។ ចាប់ពីឆ្នាំ១៩៩៣មក ពុទ្ធសាសនបណ្ឌិត្យ មានកំណើតឡើងវិញ បានផ្ដើមបោះពុម្ពផ្សាយម្ដងទៀតនូវ អត្ថបទ ពុទ្ធសាសនា និងទំនៀមទម្លាប់ប្រពៃណីជាដើម ដោយជំនួយពី <<ក្រុមប្រឹក្សាពិភពលោក ជប៉ុន ស្ដីពីសាសនានិងសន្តិភាព>> (The Japanese committee of the World Council for Religion and Peace ( WCRP) ) ពី <<គណៈកម្មាធិការជំនួយសូតូស៊ូ ជប៉ុន <<Japan Sotoshu Relief Committee for South East Asia (JRSC) >> និង <<អង្គការរិស្សូកូស៊ីកៃ>> (Reissho Kosei-Kai ) (៙១) ។ អង្គការ ក្រៅរដ្ឋាភិបាលជប៉ុន (JRSC) បានផ្ដល់ជង្រើមថ្មី ដល់វប្បធម៌ខ្មែរ តាំងពីយូរយារណាស់មក ហើយ គឺបាន បោះពុម្ពឡើងវិញនូវ សៀវភៅ មួយចំនួនធំ ចែកជាទានដល់ជនភៀសខ្លួនខ្មែរ នៅជំរំប្រទេសថៃ តាំងតែពីឆ្នាំ១៩៨០ មក ម៉្លេះ ដើម្បីខ្មែរទាំងនោះ បេះចាំវប្បធម៌ខ្លួនតទៅ ពិតមែនតែនៅឆ្ងាយពីស្រុកកំណើតក៏ដោយ ។

២) អក្សរសិល្ប៍ពីឆ្នាំ១៩៩៣ដល់១៩៩៦

ចាប់ពីថ្ងៃ២៤ កញ្ញា១៩៩៣មក ព្រះរាជាណាចក្រកម្ពុជា ឡើងគ្រងរាជជាលើកទីពីរ ដោយព្រះបាទ នរោត្តម សីហនុ វរ្ម័ន ។ ព្រះអង្គទ្រង់ជាជន្ទល់ ទ្រទ្រង់ រក្សាការពារ កេតនភ័ណ្ឌជាតិ អក្សរសិល្ប៍ និងសម្បត្តិវប្បធម៌ជាទូទៅ ។ នៅឆ្នាំ១៩៩៤ អង្គការរិស្សូកូស៊ីកៃ (Reissho Kosei-Kai) បានផ្ដល់ជំនួយ២៥០.០០០ ដុល្លាអាមេរិក ទៅ៣០០.០០០ ដុល្លាអាមេរិក សំរាប់កសាងអាគារ ធំមួយ នៃពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ តែមិនមានទីកន្លែងអាចសង់នៅឡើង ។ ព្រះមហាក្សត្រ ក៏បាន សរសេរ បុតហ្វាយ ជូន ចំពោះ នាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ ស្ដីពីការ សុំដីធ្លី ដើម្បីសង់អាគារ ធំនោះ សំរាប់ពុទ្ធសាសនបណ្ឌិត្យ កម្ពុជា (៙២) ។ វិជ្ជាស្ថាននេះ គឺជាជម្រកនិងជាស្ថាប័នយ៉ាងមាំខ្លាំក្លា អាចរក្សាការពារ សម្បត្តិវប្បធម៌ជាតិ អោយគង់វង្ស ទៅអនាគត ។ តាំងពីមានកំណើត ឡើងវិញ ពុទ្ធសាសនបណ្ឌិត្យ បានប្រស់អោយរស់ ឡើងវិញ នូវទស្សនាវដ្ដី កម្ពុជសុរិយា ដោយការឧបត្ថម្ភពីអង្គការ ក្រៅរដ្ឋាភិបាល ជប៉ុន ដូចមានចែងខាងលើនេះ ហើយ និងបានបោះពុម្ពឡើងវិញ ជាជំបូងនូវ អត្ថបទអក្សរសិល្ប៍ពុទ្ធសាសនា ។

រហូតមកដល់ឆ្នាំ១៩៩៤ អក្សរសិល្ប៍ ហាក់ដូចជានៅនឹងតាំងដំណើរ ឬក៏ធ្វើដំណើរ ដោយយឺតៗ នៅឡើយ ព្រោះអ្នកនិពន្ធយើងនៅសម័យកុម្មុយនិស្ដ (៙៣) ធ្លាប់មជ្ឈិមបក្ស ឬ គណកម្មការ នយោបាយបក្ស គឺជាអក្សរសិល្ប៍ដឹកនាំ (៙៤) ហេតុនេះហើយ បានជាស្នេរ ទាំងឡាយ គ តាំងដៃដើងស្មារតី បញ្ញា ខ្វះការ ច្នៃប្រឌិត

ផ្ទាល់ខ្លួន ម្នាក់ៗ ហើយហាក់ដូចជា ខ្វះថាមពល អ្វីមួយ មករុញច្រាន ទៅមុខ ។ ក្នុងបច្ចុប្បន្ននេះ ប្រទេសកម្ពុជា ខ្វះរបនាសម្ពន្ធ បោះពុម្ពផ្សាយ ដោយម្យ៉ាង រោងពុម្ពរដ្ឋចាស់ គំរឹល ប្រើការ មិនកើត ក្រសួងលក់ លៃ អាគារ អោយឯកជនអស់ ។ ម្យ៉ាងទៀត កម្ពុជា នៅខ្វះប្រព័ន្ធទំនើប បោះពុម្ព ផ្សាយ នៅឡើយ ហើយ ឯកជន មិន ទាន់ ហ៊ានធ្វើវិនិយោគទុន ទៅលើប្រព័ន្ធ បោះពុម្ព ផ្សាយ ដោយ មិនអាច ទាញ កំរៃ បាន គ្រប់គ្រាន់ លើវិស័យនេះ ។ អ្នកអានអត្ថបទ អក្សរសិល្ប៍ មាន ចំនួន តិច តួច ពេក ដោយ ប្រជាជន មិនសូវ មានបំណង់ ចំណូលចិត្តអាន ហើយ និង ខ្វះ ការ អប់រំ បញ្ជាក់ ដោយ អ្នក មិនចេះ អក្សរ ច្រើនពេក ក្នុងស្រុក ដូចមាន អត្រា អនក្ខរជន បង្ហាញស្រាប់ (៙៥) ។ ម្យ៉ាង ទៀត ជនានុជន ចូលចិត្ត ស្តាប់វិទ្យុ មើលរឿងក្នុងទូរទស្សន៍ និងក្នុងវីដីអូ ព្រោះងាយ យល់ ហើយសប្បាយ ជាង អក្សរ សិល្ប៍ ដោយ មិន បាច់ ចេះអក្សរ ថែម ទៀតផង ។ ហេតុនេះ ហើយ បានជា កវី និពន្ធ មិនអាច មានលទ្ធភាព រស់ នឹងសំណេរ ខ្លួនឯងបាន ព្រោះ កំរៃ ទទួលពីស្នាដៃខ្លួនតិចតួច ពេក យកទៅផ្គត់ផ្គង់ជីវិត មិន កើត ។

នៅ ចុងឆ្នាំ១៩៩៥ ព្រះករុណា ព្រះបាទ**នរោត្តម សីហនុ** បាន ចាប់ យកព្រះទ័យ ទុក ដាក់ លើ ការ តែងនិពន្ធ ដោយ ជួយ ជ្រោមជ្រែង << សមាគម អ្នក និពន្ធ ខ្មែរ >> (Association of khmer writers ) (៙៦) អោយ ប្រារព្ធ ការ ប្រឡងប្រជែង អក្សរ សិល្ប៍ យក រង្វាន់ <<ព្រះសីហនុរាជ>> លើកទី១ ។ ដោយ អវត្តមាន ព្រះមហាក្សត្រ នៅ កម្ពុជា ពិធី ប្រកាស ជ័យ លាភី ជូនរង្វាន់ អក្សរសិល្ប៍ នេះ ស្ថិតក្រោម អធិបតីភាព សម្តេច << **ជា ស៊ីម** >> ជា តំណាង ដ៏ខ្ពង់ខ្ពស់ នៃ ព្រះករុណា សម្តេច ព្រះបាទ **នរោត្តម សីហនុ វរ្ម័ន** នៅ ថ្ងៃ ២២ ខែ មករា ១៩៩៦ ដែលប្រារព្ធ ឡើងដោយ សមាគម នេះ (៙៧) ។ ផ្នែកប្រលោមលោក រង្វាន់ អក្សរសិល្ប៍ <<ព្រះសីហនុរាជ >> បំណាត់ថ្នាក់ លេខ១ បានជល់ អ្នក **ស្រីម៉ៅសំណាង** ចំពោះរឿង រលកបោកខ្សាច់ (៙៨) និង បំណាត់ថ្នាក់ទី១ ស្ទួន បានជល់ អ្នកស្រី **ចាំលំទណ្ឌារីរក្ស** ចំពោះ រឿង បំភ្លេច មិន បាន (៙៩) ។ ចំណែក ផ្នែក កំណាព្យ រង្វាន់ អក្សរ សិល្ប៍ <<ព្រះសីហនុរាជ>> បំណាត់ថ្នាក់ លេខ១ បានជល់ សុខ សុធន ចំពោះកម្រងកំណាព្យ ពេលពុកមិននៅ (៙១០) និងបំណាត់ថ្នាក់ទី១ ស្ទួន បានជល់ កញ្ញា **ប៉ុលពិសី** ចំពោះ កំណាព្យ ល្បែងជីវិត (៙១១) ។ ស្នាដៃទាំងនោះ បោះពុម្ពផ្សាយ ឡើង ដោយ ការ ជួយ ឧបត្ថម្ភ ពី មូលនិធិ **ហ៊ិនរិចប៊ុល** (Heinrich Bôll Foundation) (៙១២) ជា អង្គការ

ក្រៅរដ្ឋាភិបាល អាលីម៉ង់ (N.G.O) ហើយស្នាដៃមួយចំនួនទៀត បោះពុម្ពផ្សាយដោយការឧបត្ថម្ភពីមូលនិធិ កាណាដា (Funded by Canada Fund) (៙១៣) ។

បន្ទាប់ពីពិធីប្រកាស ជ័យលាភី <<ព្រះសីហនុរាជ>> សមាគមអ្នកនិពន្ធខ្មែរ បានប្រារព្ធពិធី បើកវគ្គ បណ្ដុះបណ្ដាល អ្នកនិពន្ធ ជំនាន់ទី ២ នៅថ្ងៃ១៦ មិនា ១៩៩៦ ក្រោមអធិបតីភាព សម្ដេចព្រះរាជបុត្រី ព្រះរៀម **នរោត្តមបុប្ផាទេវី** (៙១៤) ។ នេះជាសក្ខីភាពបញ្ជាក់ថា អក្សរសិល្ប៍កំពុងតែបោះជំហានទៅរកទិសដៅមួយមិនខាន។

នៅប្រទេស បារាំង វិទ្យុបារាំង អន្តរជាតិ បានប្រារព្ធ ការប្រឡងយករង្វាន់អក្សរសិល្ប៍ផ្នែកកំណាព្យ នៅឆ្នាំ១៩៩៤ (៙១៥) ។ ចំណែក <<សមាគមអ្នកនិពន្ធខ្មែរនៅបរទេស>> (A.E.K.E) (៙១៦) បានធ្វើរាត្រីសមោសរជាច្រើនលើក ដើម្បីអោយបានកំរៃខ្លះៗ យកជាជំនួយឧបត្ថម្ភការផ្ដល់រង្វាន់ និងការបោះពុម្ពសៀវភៅ <<ជ័យលាភី រង្វាន់សន្តិភាព>> (៙១៧) ។ ការប្រកាសប្រឡងយកជ័យលាភីនេះ ផ្ដើមឡើងនៅឆ្នាំ១៩៩៥ ហើយពេលបញ្ចប់ការទទួលស្នាដៃអក្សរសិល្ប៍ គឺចាប់ពីថ្ងៃ១៨ ធ្នូ១៩៩៦ ។ <<សមាគមអ្នកនិពន្ធខ្មែរ នៅបរទេស>> បានរៀបចំគណៈកម្មការ មេប្រយោគ កំណែស្នាដៃអក្សរសិល្ប៍ទាំងឡាយ នៅឆ្នាំ១៩៩៧ ដោយមាន បណ្ឌិត **ឃីង ហុកឌី** ជាប្រធានកិត្តិយស កំណែអក្សរសិល្ប៍ដើម្បីយក<<ជ័យលាភីរង្វាន់សន្តិភាព>>(៙១៨) ។

៣) អក្សរសិល្ប៍ពីឆ្នាំ១៩៩៧ ដល់បច្ចុប្បន្ន

សមាគមអ្នកនិពន្ធខ្មែរនៅបរទេស បានប្រកាស <<ជ័យលាភី រង្វាន់សន្តិភាព ១៩៩៧>> នៅរវាងខែកញ្ញា ។ ចំណាត់ថ្នាក់ លេខ១ បានដល់ លោក**ឌៀប គឹមហ៊ាង** (៙១៩) នៅបារាំង ចំពោះប្រលោមលោក មានចំណងជើងថា <<ក្រឡេកមើលភ្លើងឆេះស្រុកខ្មែរ ...ពីត្រើយម្ខាង>>(៙២០); ចំណាត់ថ្នាក់ លេខ២ បានដល់លោក**ញ៉ៀបដាបឡេង** នៅបាត់ដំបង ចំពោះប្រលោមលោក << ឈាមភក្ដី>> (៙២១);ចំណាត់ថ្នាក់ លេខ៣ បានដល់ លោក **នឹម ឈរ៉ា** នៅភ្នំពេញ ចំពោះប្រលោមលោក << សំណោកជីវិត>> ហើយនិងរង្វាន់កិត្តិយស ៣ទៀត ដែលជារង្វាន់លើកទឹកចិត្តរបស់<<សមាគមអ្នកនិពន្ធខ្មែរនៅបរទេស >> ជូនចំពោះអ្នកនិពន្ធខ្មែរនៅក្នុងស្រុក ។ ការប្រគល់ជ័យលាភី ពានរង្វាន់ អក្សរសិល្ប៍ សន្តិភាព លើកទី១ បានប្រារព្ធ នៅទីស្នាក់ការ កណ្ដាល សមាគមអ្នកនិពន្ធខ្មែរ ដែលមានទីស្នាក់ការនៅក្នុងវត្តបទុមវតី កាលពីថ្ងៃ២ កញ្ញា១៩៩៧(៙២២)។ ប៉ុន្តែការបែក ពាន

រង្វាន់អក្សរសិល្ប៍ សន្តិភាព លើកទី១ នេះ នៅប្រទេសបារាំងប្រារព្ធ នៅថ្ងៃទី១ ឧសភា ១៩៩៨ ប៉ុណ្ណោះ ។

នៅកម្ពុជាវិញ ក្នុងដើមឆ្នាំ១៩៩៧ សមាគមអ្នកនិពន្ធខ្មែរ បានផ្តើមរៀបចំធ្វើការប្រឡងយក<<រង្វាន់អក្សរសិល្ប៍៧ មករា >> ក្រោមអធិបតីភាព សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី ទី២ នៃរាជរដ្ឋាភិបាល កម្ពុជា និងជំទាវ ប៊ុន រ៉ានី ។ បំណាត់ថ្នាក់លេខ១ ខាងប្រលោមលោក បានជូនចំពោះលោក អ៊ុនសុខឃាង ដែលបាននិពន្ធរឿង ថ្ងៃមិនរុះរោយ (៙២៣)។

នៅថ្ងៃ១៧ធ្នូឆ្នាំ១៩៩៧ សមាគមអ្នកនិពន្ធខ្មែរ បានរៀបចំធ្វើពិធីប្រកាសជ័យលាភី ជូនរង្វាន់<<ព្រះសីហនុរាជ>> លើកទី២ ក្រោមអធិបតីភាព ព្រះអគ្គមហេសី ព្រះមុនីនាថសីហនុ ។ បន្ទាប់មកអ្នកកវីនិពន្ធ ដែលជាប់ចំណាត់ថ្នាក់នានា បានចូលគាល់ព្រះមហាក្សត្រ នៅថ្ងៃ២៣ធ្នូ១៩៩៧ ។

ក្នុងរយៈពេលពីឆ្នាំ១៩៩៣ មកដល់បច្ចុប្បន្ន នេះ អ្នកកវីនិពន្ធខ្មែរ នៅបរទេស ពិតមែនតែនៅឆ្ងាយពីស្រុកកំណើត ឬឋិតក្នុងសភាពលំបាកនៃជីវិតនៅតតិយប្រទេសក៏ដោយ ក៏មិននៅឱបដៃនៅស្ងៀម មិនគិតគូរទៅស្រុកទេសនោះទេ ។ អ្នកកវីនិពន្ធខ្មែរ ខ្លះៗ បានខិតខំសរសេរ ជាកំណាព្យ ប្រលោមលោក សិក្សាកថានានា ចង់ផ្សព្វផ្សាយអោយទៅដល់បងប្អូន និងប្រជាជនខ្មែរទាំងមូល នៅកម្ពុជា និងនៅបរទេស (៙២៤)។

ក្នុងឆ្នាំ ១៩៩៧-១៩៩៩ នេះ នៅបរទេស ដូចជាអាមេរិក អឺរ៉ុប ជប៉ុន ជាដើម ខ្មែរអ្នកចេះដឹងយើងនៅតែមាន សមានចិត្តចង់ផ្សព្វផ្សាយចំណេះដឹងខ្លួនម្នាក់ៗ ទៅជាប្រជាជនខ្មែរជាទូទៅ ។ នៅអឺរ៉ុប ជាពិសេសនៅប្រទេសបារាំង អ្នកស្រាវជ្រាវខ្មែរ ខំសរសេរសិក្សាកថា ជាភាសាជាតិ ក្នុងគោលបំណងអោយសិស្ស និងនិស្សិតខ្មែរក្នុងស្រុក ដែលមិនចេះភាសាបរទេស បានក្រេបជញ្ជក់ចំណេះដឹង បែបវិទ្យាសាស្ត្រផង (៙២៥) ហើយអ្នកនិពន្ធក៏បានខំតែងប្រឌិតអត្ថបទអក្សរសិល្ប៍ដែរ (៙២៦) ។

លោក ឡួន គន ជាអតីតសាស្ត្រាចារ្យ សកលវិទ្យាល័យវិចិត្រសិល្បៈកម្ពុជា និងអតីតសាស្ត្រាចារ្យ ភាសាខ្មែរ នៅ សកលវិទ្យាល័យ តូក្យូ ( Tokyo University of Foreign Studies ) ហើយសព្វថ្ងៃចូលនិវត្តន៍ត្រឡប់ទៅរស់នៅ សហរដ្ឋអាមេរិកវិញ លោកបានផ្សាយស្នាដៃ៣ ក្នុងឆ្នាំ១៩៩៩នេះ គឺកម្រងអត្ថបទអក្សរសិល្ប៍ (សិក្សាកថានិងកំណាព្យ) និង

រឿងល្ខោន២ ទៀត ដោយមាន ខ្សែអាត់ ថត ភ្ជាប់ ផង(៙២៧) ដោយ ចង់ អោយ ប្រជាជន ខ្មែរ ទូទៅ បងចាំនូវ សោកនាដកម្ម នៅ សតវត្សទី២០ ដើម្បី ចៀសវាងកុំ អោយ រឿងនេះ កើត មាន ឡើងវិញ ទៀត នៅ កម្ពុជា ។ នៅប្រទេស ជប៉ុន មាន ការ តែងនិពន្ធ ជាភសាខ្មែរ ផ្នែក ប្រលោមលោក(៙២៨) និងសិក្សាកថា (៙២៩) ដែរ ។

សព្វថ្ងៃ មជ្ឈមណ្ឌល ឯកសារ ស្រាវជ្រាវ អារ្យធម៌ ខ្មែរ(៙៣០) ដែលចាប់កំណើត ដំបូងនៅក្រុងប៉ារីស ប្រទេសបារាំងហើយ ដោយ ឯ.ឧ ប្រធាន នុតណារ៉ាង បាន ត្រឡប់ ទៅ ធ្វើ រដ្ឋ មន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បះ នៅ ភ្នំពេញ រហូត មក ដល់ ខែកក្កដា ឆ្នាំ ១៩៩៨ គឺ ពេល ដែល ជាប់ ឆ្នោត ជា តំណាងរាស្ត្រ នៅ តំបន់ក្រចេះ ។ ហេតុនេះហើយ បាន ជា មជ្ឈមណ្ឌល នេះ នៅនឹង ដោយ ព្យួរ ចោល សកម្មភាព មួយ រយះ ពេល គឺ ពី ឆ្នាំ១៩៩០ រហូត មកដល់ ឆ្នាំ១៩៩៩ ។ សព្វថ្ងៃ មជ្ឈមណ្ឌល ឯកសារ ស្រាវជ្រាវ អារ្យធម៌ ខ្មែរ បានផ្តើមសកម្មភាព ឡើងវិញ គឺ ចាប់បោះផ្សាយ ឡើងវិញ នូវ ទស្សនាវដ្តី កូន ខ្មែរ ជាភាសា ជាតិ និងទស្សនាវដ្តី សិក្សា ខ្មែរ (៙៣១) ជា ភាសា បស្ចិមប្រទេស និងភាសា ខ្មែរ ហើយ ថ្មីៗ នេះ បានបោះពុម្ព ឡើងវិញ នូវ ប្រលោមលោក ចាស់ មួយ សរសេរ ឡើង ដោយ អ្នកស្រី ស៊ុយ ហៀង នៅ ឆ្នាំ១៩៨៣ (៙៣២) ដោយ មាន បន្ថែម អារម្ភកថា លោក ប្រធាន នៃ មជ្ឈមណ្ឌល នេះផងដែរ ។

៤) សិក្សាកថា អត្ថបទវិទ្យាខ្លះៗ

ប្រលោមលោក រលក បោកខ្សាច់ និពន្ធ ដោយ អ្នកស្រី ម៉ៅសំណាង (៙៣៣) ដែល បាន ទទួលរង្វាន់ អក្សរសិល្ប៍ បំណាត់ថ្នាក់ លេខ១ ។ ស្នាដៃ នេះ មាន កថាមុខ ដោយ អ្នកស្រី បណ្ឌិត ហេម៉ា ហ្គូណាធីឡាគែ (Hema Goonatilake) ជា តំណាង មូលនិធិ Heinrich Bôll សំដែង សេចក្តីគោរព សរសើរ ដល់ កវី-និពន្ធនារី ខ្មែរ បន្ទាប់ មកមាន វាចា លោក យូ ប៊ូ ជា ប្រធាន សមាគម អ្នកនិពន្ធខ្មែរ ដោយ រាយ នាម អ្នកនិពន្ធ ដែលបានទទួលជ័យលាភី និង អំណរគុណ ផ្សេងៗ ហើយនិងវាចា អ្នកនិពន្ធ ។ រលក បោកខ្សាច់ សរសេរ ក្នុងរបនាបទ ល្អ ងាយ យល់ អ្នកអាន អាច ចាប់ សេចក្តីរឿងបានស្រួល ។ រឿងនេះ ចែកជា៧វគ្គ គឺជា ស្នាដៃនារី ពោរពេញ គំនិតស្ត្រីនិយម អោយតម្លៃជំមុះមុត ទៅ លើប្រពៃណី ទំនៀមទម្លាប់ ខ្មែរ ការពារ ដោយតួអង្គ យុវនារី កញ្ញា បុស្សបា ។ នាងបាន ខំតស៊ូ ពុះពារ ហើយបាន សម្រេច ជោគជ័យ លើកិច្ច អនាចារ នៃ សង្គម ទំនើប ដែលពោរពេញ ដោយ ការ កេងប្រវញ្ចន៍ និងពេស្យាចារ ជាដើម ។

ចំពោះប្រលោមលោក ដែលបានទទួល រង្វាន់ អក្សរសិល្ប៍ << សន្តិភាព១៩៩៧>> ក្រុងប៉ារីស ចំណាត់ថ្នាក់ លេខ១ គឺរឿង<< ក្រឡេកមើល ភ្លើងឆេះ ស្រុកខ្មែរ ...ពីត្រើយ ម្ខាង >> និពន្ធដោយលោក ឡៀបគីម ហ៊ាន គណៈមេប្រយោគ បានធ្វើសេចក្ដីសង្កេត ខ្លះៗដូចតទៅនេះ ៖

១)<< បង្ហាញ សក្ខីភាព និងប្រវត្តិ ផ្ទះខ្មែរ នៅ បូរី សាកលវិទ្យាល័យ ប៉ារីស និង ជីវភាព ទំនាក់ទំនង និងទំនោរនយោបាយ នានា នៃក្រុមនិស្សិតខ្មែរ នៅប្រទេសបារាំង ។

<<- អនុស្សាវរីយ៍ អតីតនិស្សិតខ្មែរ នៅបរទេស ដែលត្រឡប់ទៅស្រុកខ្មែរ ក្នុង សម័យ ប៉ុល ពត ។

<<-ឧត្តមគតិ តំរិះ រកសន្តិភាព តាមរយៈតួអង្គ>>(បណ្ឌិត ឃឹង ហុកឌី) ។

២)<<អ្នកនិពន្ធមានទស្សនៈប្រាកដនិយមក្នុងការវិនិច្ឆ័យទៅលើ ឈុតសោកនាដកម្ម ក្នុងសាវតារ បច្ចុប្បន្ន នៃភូមិដែលសរសេរ ដោយអក្សរ លោហិត ។

<< ពាក្យពេចន៍ មានរស ជាតិពិរោះ និង កំប្លែងស្លូត តំរូវ នៅតាមធន្ទះ និង មនោសញ្ចេតនា របស់តួអង្គទាំងពីរ ដែលចង់ជំនះព្រហ្មលិខិត>> (គីម ខុទនី)

៣)<< អ្នកនិពន្ធ មាន ស្មារតី ប្រាកដនិយម លាយឡំជាមួយ រឿង នយោបាយ ក្នុង អតីតកាល និង បច្ចុប្បន្នកាល លាយឡំវប្បធម៌ ខ្មែរខ្លះ ។ អ្នកចូលចិត្ត ចង់ដឹងរឿងមុន ឆ្នាំ១៩៧០ និង ក្រោយ ឆ្នាំ១៩៧០ អាចក្រេបរសជាតិ សាច់រឿង ។ ជាពិសេស ភាពពិត នៅក្នុងផ្ទះខ្មែរ មុនឆ្នាំ១៩៧០>>(នុត ឈឿម) ។

៤)<<ផ្ទុះព្រឹត្តិការណ៍ ពិតជាក់ស្ដែង របស់និស្សិតខ្មែរ ក្នុងផ្ទះខ្មែរ នាទីក្រុងប៉ារីស ។

<<-ប្រវត្តិស្នេហាប្រកប ដោយការ ភ្ញាក់ រឭក ចំពោះហេតុ និងអំពើកន្លងមក ។

<<-សាច់រឿង មាន ខ្លឹមសារ មាន ឧត្តមគតិ ជារឿងល្អ អាចចាត់ទុក ជាបំណីអារម្មណ៍ថ្មីសំរាប់យុវជន ជំនាន់ក្រោយ ។

<<-អហឹង្សា ការ មានគំនិតសាមគ្គី បេះលះបង់ការប្រណែននិន្ទា ឈ្នានិស គំនិតស្វែងរក រក សេចក្ដីសុខ សន្តិភាព ដែលតួអង្គឯក ក្នុងរឿងនេះ បានប្រព្រឹត្ត នៅ ក្នុង ដំណើរជីវិតគឺ ជាវីរភាព មួយ កម្រជួបប្រទះ...>> ( អ្នកស្រី ម៉ិចសទ្ធាវ៉ាន) ។

ក្រោយឆ្នាំ១៩៩៦ មកកម្ពុជា បានទទួលបទពិសោធន៍ច្រើនទាំងលើផ្នែកនយោបាយ និងសេដ្ឋកិច្ច គឺប៉ុលពតបានស្លាប់ ចលនាខ្មែរក្រហមរលត់ជីវិត សម្ដេច នរោត្តមរណឫទ្ធ និង សម្ដេច ហ៊ុន សែន ជានាគ្នា មករស់ នៅ ក្នុងប្រព័ន្ធនយោបាយ និងអំណាចរួម ហើយ

ដំណឹងចុងក្រោយ គឺ កម្ពុជា បាន ចូលជា សមាជិក ASEAN ។ អក្សរសិល្ប៍ រហូត មកដល់ ថ្ងៃនេះ បាន បោះជំហាន សន្សឹមៗ និង នៅ ក្មេងខ្ចី នៅ ឡើយ ពិតមែន តែបានទទួលជំនួយ ខ្លះៗ ក៏ដោយ ។ ហេតុនេះ ទៅ អនាគត ដើម្បីធ្វើអោយ អក្សរសិល្ប៍រីកចំរើនគួរ តែខ្មែរ ក្នុងស្រុក និងក្រៅស្រុក ពួតដៃគ្នា កសាង រួម និង រក មធ្យោបាយ នានា ដើម្បី ពង្រីក ពង្រឹង មែកធាង នេះ អោយ មាន ជំហារ មាំមួន ទាន់អារ្យប្រទេស ។ ហេតុនេះ គួរ ធ្វើយ៉ាងណា អោយ អក្សរស្រិល្ប៍ លូតលាស់ទៅ មុខ ព្រោះជា ឫសកែវ និង ជា ជន្ទល់ សង្គម ទៅ រក ចំណេះដឹង សន្តិភាព វឌ្ឍនភាព សាមគ្គីភាព ភាតរភាព ។ល។ សេចក្តីសង្ឃឹម ទៅអនាគតម្យ៉ាង គឺ ថា នឹងមាន អក្សរសិល្ប៍ ចំរុះ ដើម្បី ឲ្យ មានការ ប្តូរ យោបល់ មតិ មនោគមវិជ្ជា ទស្សនវិជ្ជា និង ចំណេះ ដឹង នានា មិន មែន ជា អក្សរសិល្ប៍ ដឹកនាំបែប ប្រទេសកុម្មុយនិស្តបាស់គំរីលទេ ដែល ធ្វើឲ្យ អ្នកនិពន្ធបង្អៀតបង្អល់ មិនអាចរិះគិតតែង សំដែង តាម បំណង់ បំណូល ចិត្ត និង ចំណេះ ដឹង ម្នាក់ៗ បាន ។ ម្យ៉ាងទៀត អក្សរសិល្ប៍ អាចមានថាមពល នឹងជួយពង្រឹងអត្តសញ្ញាណយើងឲ្យនៅ ជាខ្មែរ និងឲ្យមាន មោទនភាព ជា ខ្មែរ ដោយ បណ្តុះ គំនិតស្នេហាជាតិ មាតុភូមិជាដើម ។ សព្វថ្ងៃ នេះ ក្នុងពិភពលោក ប្រព័ន្ធ សោតទស្សន៍ រីក ដុះដាល ជា អនេក គួរ បារម្ភ ។ ហេតុនេះក្រសួងមាន សមត្ថកិច្ច ទាំងឡាយ គួរ រិះរកមធ្យោបាយ សំយោគ ស្វ ខ ប្រព័ន្ធ សោតទស្សន៍ នេះយក ជា កត្តា ទៅពង្រីកពង្រឹងអក្សរសិល្ប៍យើងវិញ ដើម្បីឲ្យ មែកធាងអរិយធម៌នេះ មានស្ថិរភាព និង វឌ្ឍនភាព ទៅ មុខ ពោលគឺ មិន មែន យក ប្រព័ន្ធនេះ មក សង្កត់ ជាន់ឈ្លី សម្លាប់ អក្សរសិល្ប៍យើងឡើយ ។៚

ចំណារចំណាំ.-

(៙១) សៀវភៅ ទាំងនេះ បោះពុម្ព ឡើង ដោយ ជំនួយ អង្គការសាសនា នៃប្រទេស ជប៉ុន ដូច មាន បញ្ជាក់ លើ សៀវភៅនីមួយៗស្រាប់ដោយចំណារផ្សេងៗដូចជា៖ << សៀវភៅធម៌ត្រូវបានបោះពុម្ពឡើងជាពិសេសទុកដូចជាគម្រោង ការងារ សហប្រតិបត្តិការ របស់ក្រុម ប្រឹក្សា ពិភពលោក ជប៉ុន ស្តីអំពី សាសនា និង សន្តិភាព ( WCRP) ហើយនិង គណៈកម្មការ ជំនួយ សូតូស៊ូ ជប៉ុន (JRSC) ឬThis book has been printed by Japan Sotoshu Relief Committe (JRSC) with the contribution from Reissho kosei-Kai. We pray that his book would contribute to the friendship with Cambodian people and their religious and cultural preservation >> ។

(៙២) សូមអាន កម្ពុជា សុរិយា លេខ២ ឆ្នាំទី៤៨ មេសា–ឧសភា–មិថុនា១៩៩៤ ទំព័រ១។ អាគារពុទ្ធសាសន បណ្ឌិត្យទើបនឹងសម្ពោធនៅឆ្នាំ១៩៩៨។

(៙៣) កវីនិពន្ធ សមាជិកសមាគមអ្នកនិពន្ធ កម្ពុជា សម័យសាធារណរដ្ឋប្រជាមានិត កម្ពុជា នៅ សរសេរតទៅ ទៀត តែតែងនិពន្ធដោយសេរី លែងគោរពតាមបន្ទាត់នយោបាយ បក្សកុម្មុយនិស្តទៀតហើយ។ សូមអាន ស្នាដៃ លោក**គង្គ**

**ប៊ុន ឈឿន** (អតីតអគ្គលេខាធិការ សមាគមអ្នកនិពន្ធកម្ពុជា) **វិជ្ជលឯកត្តំ** ប្រលោមលោកផ្នែកជីវិតលោក ភ្នំពេញ ១៩៩៥ កម្រាស់១៤៧ទំព័រ; **ទន្លេះដាវតព្យាយ៉ាត** ប្រលោមលោកផ្សងព្រេង ផ្នែកយុទ្ធគុន ភ្នំពេញ១៩៩៥ ពីរភាគ; **ផ្លូវសត្យា** ភ្នំពេញ១៩៩៥ បីភាគ; **អំពិលអំពែក** ភ្នំពេញ១៩៩៥ កម្រាស់១២៤ទំព័រ; **ព្រាយក្លាមស្រម៉ៃ** ភ្នំពេញ១៩៩៧ កម្រាស់១១១ទំព័រ។ **ជុំការណាល់** រឿង **ខុសបំណង** ភ្នំពេញ១៩៩៦ កម្រាស់២៤ទំព័រ; **ស្វែងយល់អក្សរសិល្ប៍សង្ខេបបែបនំនើបទូទៅ** ភ្នំពេញ១៩៩៦ កម្រាស់៧៤ទំព័រ។ ជ័យចាប **កំរងពាក្យបណ្តៅខ្មែរ** ភ្នំពេញ១៩៩៥ កម្រាស់៣២ទំព័រ។

(៙៤) ចំពោះបញ្ហានេះ សូមអានសេចក្តីពិស្តារក្នុងអត្ថបទជាភាសាបារាំងរបស់លោក**តូចឈួន** មន្ត្រីជាន់ខ្ពស់ក្នុងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ Tauch Chhuong, << Les publications au Cambodge après 1990 >> , in Pierre L.Lamant (éd) , Bilan et perspectives des études khmères ( langues et culture ), Actes de Colloque de Phnom Penh 29-30 -1er décembre 1995 , Paris , L'Harmattan , 1997, p 43-62. លោក**តូចឈួន** បានបោះពុម្ពផ្សាយឡើងវិញនូវសៀវភៅដែលលោកសរសេរនៅមុនឆ្នាំ១៩៧៥ **បាត់ដំបងសម័យលោកម្ចាស់** បោះពុម្ពផ្សាយក្រោមការឧបត្ថម្ភនៃមជ្ឈមណ្ឌល បូព៌ា–បស្ចិម ក្រុងហូណូលូលូរដ្ឋហាវៃ ភ្នំពេញ១៩៩៤ កម្រាស់២៣៣ទំស័រ; សៀវភៅនេះបកប្រែជាភាសាអង់គ្លេស Battambang during the time of the Lord Governor , translated by Hin Sithan , Carol Morthland and Judy Ledgerwood, publications Funded East Center Honolulu Hawaï, Phnom Penh 1994 , 143 p.

(៙៥) អត្រាអ្នកមិនចេះអានមានចំនួន៦២% នៅប្រទេសកម្ពុជា សូមអាន << Une presse peu lue >>, la lettre de Reporters sans frontières 7 , n° 85,24 Juin 1996.

(៙៦)លោក**យូប៊ូ** បានពង្រស់ឡើងវិញ ក្នុងឆ្នាំ១៩៩៣ នូវ<<សមាគមអ្នកនិពន្ធខ្មែរ>> បែបសម័យសង្គមរាស្ត្រនិយម ដែលមិនមែនជាសមាគម ផ្លូវការ បង្កើត ឡើងក្រោម រដ្ឋាភិបាល កុម្មុយនិស្ត នៃសាធារណរដ្ឋ ប្រជាមានិត កម្ពុជាក្នុងរយៈពេលឆ្នាំ១៩៨០-១៩៩០ទេ ។ លោក**យូប៊ូ** នៅជាប្រធានសមាគមអ្នកនិពន្ធខ្មែរ ពីឆ្នាំ១៩៩៣ដល់១៩៩៦ ។ ចាប់ពីឆ្នាំ១៩៩៧ មក លោក**ជ័យចាប** (អតីតសាស្ត្រាចារ្យ អក្សរសិល្ប៍ខ្មែរ នៅសកលវិទ្យាល័យភ្នំពេញ ហើយសព្វថ្ងៃមានតួនាទីជាអនុរដ្ឋលេខាធិការក្រសួងអប់រំជាតិ) បានឡើងធ្វើជាប្រធានហើយលោក**យូប៊ូ**ជាអនុប្រធានទី១។

(៙៧) សូមអានទស្សនាវដ្តីអ្នកនិពន្ធខ្មែរ លេខ២ ខែវិច្ឆិកា ១៩៩៥ ទំព័រ៣-៦ ។ << ពិធីប្រកាសលទ្ធផល និងជូនរង្វាន់ស្នាដៃអក្សរសិល្ប៍ព្រះសីហនុរាជ>> សារពត៌មានរស្មីកម្ពុជា ថ្ងៃព្រហស្បតិ៍ទី២៥ ខែមករាឆ្នាំ១៩៩៦;<< លេខ១ពីរនាក់>> សារពត៌មានរស្មីកម្ពុជា ថ្ងៃសៅរ៍ទី២៧ ខែមករាឆ្នាំ១៩៩៦; << ស្លឹកឈើ ដុះចេញពីគល់>> សារពត៌មានរស្មីកម្ពុជា ថ្ងៃទី២៨ ខែមករាឆ្នាំ១៩៩៦;<< **សុខសុធន** កវីពានរង្វាន់មាស>> សារពត៌មានរស្មីកម្ពុជា ថ្ងៃទី៣១ ខែមករាឆ្នាំ១៩៩៦ ។

(៙៨) **ម៉ៅសំណាង** រលកខ្យាច់(The waves)ភ្នំពេញ ការផ្សាយរបស់សមាគមអ្នកនិពន្ធខ្មែរ ១៩៩៦ កម្រាស់ ១៤៥ទំព័រ។សូមអានអត្ថបទអ្នកស្រី**ឪុល សម្បត្តិ** << នេះគឺការងារប្រចាំថ្ងៃរបស់អ្នកស្រី>>

(៙៩) **ប៉ាល់ វណ្ណារីរក្ស** បំភ្លេចមិនបាន *ភ្នំពេញ ការផ្សាយរបស់សមាគម អ្នកនិពន្ធខ្មែរ ១៩៩៦ ; កម្រាស់២៨៧ទំព័រ។*

(៙១០) **សុខ-សុធន** កំណាព្យ ពេលពុកមិននៅ (As Father is away ) ភ្នំពេញ *ការផ្សាយរបស់សមាគម អ្នកនិពន្ធខ្មែរ ១៩៩៥; កម្រាស់៨២ទំព័រ។*

(៙១១) កញ្ញា **ប៉ុល ពិសី** កំណាព្យ ល្ខោនជីវិត (The theater of Life ) ភ្នំពេញ *ការផ្សាយរបស់សមាគម អ្នកនិពន្ធខ្មែរ ១៩៩៦; កម្រាស់ ៩០ទំព័រ។ សូមអានអត្ថបទអ្នកស្រី* **អ៊ុងវណ្ណា**

*<<នាងបេះសរសេរកំណាព្យ តាំងពីអាយុ ៨ ឆ្នាំ* **(**She has composed poem since she was 8 years old " សម្លេងស្ត្រីខ្មែរ " **(** khmer women's Voice **)** *ទស្សនាវដ្ដី ២ ភាសា លេខ ៤/៩៦ ទំព័រ* ***១៨-២៣*** **)** *ฯ*

(៙១២) Cf. Klairung Amratisha, The Cambodian Novel : A study of its Emergence and Development , University of London , School of Oriental and African Studies , Ph.1998,p328.

(៙១៣) **ហ៊ឹង តារាវណ្ណ** រឿងភក្ដីស្នេហ៍ (Loyal love ) ភ្នំពេញ ឧបត្ថម្ភដោយមូលនិធិ កាណាដា ការផ្សាយរបស់សមាគមអ្នកនិពន្ធខ្មែរ ១៩៩៧ កម្រាស់១១៦ទំព័រ។

(៙១៤) << ពិធី បើកវគ្គ បណ្ដុះបណ្ដាលអ្នកនិពន្ធជំនាន់ទី២ >> ទស្សនាវដ្ដី អ្នកនិពន្ធខ្មែរ លេខ៣ ខែកុម្ភៈ ១៩៩៦ ទំព័រ៤-១០ ។

(៙១៥) ចំណាត់ថ្នាក់លេខ១ **អ៊ុនសំអាន** ( កំណាព្យ ÷ កម្ពុជាភូមិកំណើតខ្ញុំ) លេខ២ **ទីសុវណ្ណ** ( បណ្ដាំឪពុកទុកឱ្យកូន) លេខ៣ **ជួនជា** ( អាងអន្តរាយស្ដាយខ្លួន) ។ល។

(៙១៦) សមាគមនេះ មាន កំណើត ចាប់តែ ពី ឆ្នាំ ១៩៨៩ មក ម្ល៉េះ មាន អ្នកស្រី **ម៉ិច សខ្វាវ៉ាន** ជាប្រធាន អនុប្រធាន÷ លោក**ជុតខៃ** និង**អ៊ុំ ហួត** អគ្គលេខាធិការ÷**ជៀបគីម ហ៊ាង** ទិប្រឹក្សា មាន÷ អ្នកស្រី **ស៊ុយ ហៀង** លោក **ប៊ីច នៃលាង ឃីង ហុកឌី សុទ្ធប៉ូលីន** និង **ខូវគីមនី** ។

(៙១៧) << សមាគមអ្នកនិពន្ធខ្មែរនៅបរទេស>> បានធ្វើរាត្រីមិត្តភាព សាមគ្គីភាព នៅពេលថ្មីៗ នេះ គឺ នៅថ្ងៃ ១៤ មិថុនា១៩៩៦ នៅប៉ារីសទី១៣ ។

(៙១៨) បណ្ឌិត **ឃីងហុកឌី** ប្រធានកិត្តិយស លោក**ខូវគីមនី** អនុប្រធានកិត្តិយស អ្នកស្រី**ម៉ិចសខ្វាវ៉ាន** ប្រធានសមាគមអ្នកនិពន្ធខ្មែរនៅបរទេស និងសមាជិក៨នាក់÷ លោក**ជុតខៃ** លោក**នុតឈឿម** លោក**ជាម៉ូណា** កញ្ញា **លាំគៀង ខា ហួងថាវី** វេជ្ជបណ្ឌិត **គាលី សាមើឌី ឆវី** ( ប្រធាន សមគម ឱសថការី ខ្មែរ នៅ ប្រទេសបារាំង ) អ្នកស្រី **ឃុនវ៉ារី** វេជ្ជបណ្ឌិត **ត្រាន់សេង** ( ប្រធានសមាគមវេជ្ជបណ្ឌិត ខ្មែរនៅបរទេស) វេជ្ជបណ្ឌិត **ឡោគីមសុង** ។

(៙១៩) **ជៀប គីម ហ៊ាង** កើតនៅថ្ងៃ១៨ ធ្នូ នៅឃុំស្វង ស្រុកត្បូង ឃ្មុំ ខេត្តកំពង់ចាម ។ ក្រោយពីប្រឡងជាប់មធ្យមសិក្សាប័ត្រទី២ លោកបានសិក្សាចប់នៅមហាវិទ្យាល័យក្សេត្រសាស្ត្រចំការដូងជំនាន់ទី១ ផ្នែកបសុពេទ្យ ។ បន្ទាប់មក បាន អាហារូបករណ៍ មកមន្តការ សិក្សា ក្នុង ប្រទេស បារាំង បាន សញ្ញាប័ត្រ ៤ ទៀត នៅវិទ្យាស្ថាន ជាតិ ក្សេត្រ សាស្ត្រ ( Instiutut national agronomique Paris Grignon ) និងវិទ្យាស្ថាន នានា ទៀត នៅ ក្រុង ប៉ារីស ។ ចំពោះរង្វាន់ ជាប្រាក់ លោក បានប្រគល់ជូនជាវិភាគទានដល់សមាគមអ្នកនិពន្ធខ្មែរនៅបរទេសវិញ។

(៙២០ ) **ជៀបគីមហ៊ាង** ក្រឡេកមើលភ្លើងឆេះស្រុកខ្មែរ... ពីត្រើយម្ខាង, ប៉ារីស ការផ្សាយពីសមាគមអ្នកនិពន្ធខ្មែរនៅបរទេស ១៩៩៧ កម្រាស់១៦៩ ទំព័រ ។

(៙២១) **ញៀបជាបឡេង** ឈាមភក្ដី ប៉ារីស ការផ្សាយពីសមាគមអ្នកនិពន្ធខ្មែរនៅបរទេស ១៩៩៧ កម្រាស់៦០ ទំព័រ ។ លោកជាពេទ្យនៅខេត្តបាត់ដំបង។

(៙២២) សូមអានកាសែត កម្ពុជាថ្ងៃនេះលេខ០១០៨ ថ្ងៃ០៤-០៥-កញ្ញា១៩៩៧ និងភ្នំពេញថ្មី លេខ៣២ ថ្ងៃ ១២-១៣កញ្ញា១៩៩៧ ។

(៙២៣) សូមអាន ទស្សនាវដ្ដីអ្នកនិពន្ធខ្មែរ លេខ៧ ខែ មករា១៩៩៧ ទំព័រ១-១៥ ។

(៙២៤) សូមអាន បញ្ជីសៀវភៅក្នុងអត្ថបទ សិក្សា **ឃីងហុកឌី** << អក្សរសិល្ប៍ខ្មែរក្រោយឆ្នាំ១៩៩០>>, in: Sorn Samnang (Ed.), Knowledge of the past and its contributions to the rehabitation and reconstruction of Cambodia , Vol II , Proceedings of International Conference on Khmer Studies, Phnom Penh, 26-30 August 1996, សាកលវិទ្យាល័យ ភូមិន្ទភ្នំពេញ មិនា១៩៩៩ ។

(៙២៥) **ឃីង ហុកឌី** ទិដ្ឋភាពនៃអក្សរសាស្ត្រខ្មែរ (Aperçu général sur la littérature khmère ) , Paris, L’Harmattan ,1997,206pages, **រស់ ចន្ត្រាបុត្រ** ប្រវត្តិសាស្ត្រខ្មែរ ភាគ១ ( ភាគរឿងព្រេង និទាន និង តាមរយៈសិលាចារឹក) ចំណងជើង ជាភាសា បារាំង Histoire du Cambodge , Partie légendaire et lapidaire , Paris , L’Harmattan, 1998, 290pages.

(៙២៦) អ្នកស្រី **ទ៉ាន់ឌីអាយខេង**, រឿងអាថ៌កំបាំងនៅភូមិព្រៃករលួស, Québec, Editions Apsara, 1997, 350 ទំព័រ (អ្នកស្រីជាភរិយាលោក**ទ៉ាន់ឌីការុន** បាននិពន្ធនៅក្រុងប៉ារីសក្នុងឆ្នាំ១៩៩៥ ។ រឿងនេះមានទាំងអស់២៣ ជំពូកលាតត្រដាងនូវបុគ្គលិកលក្ខណៈរបស់តួអង្គ១២នាក់ដែលរស់នៅកសិដ្ឋានមួយនៅភូមិព្រៃករលួសក្នុងខេត្តកំពង់ចាម...។

(៙២៧) សូមអាន **នួនកន** កម្រងអត្ថបទ ,Long Beach , ១៩៩៩, ៨៤ទំព័រ; រឿងព្រលឹងចងពៀរ ចំណងជើងជាអង្គ្លេស, The Dead Accuse Long Beach , ផ្នែកកសិណនៃកាលសោកនាដកម្ម សតវត្សទី២០, ១៩៩៩, ៤៩ទំព័រ + ខ្សែអាត់ NK 61834; រឿង ព្រលឹង យុត្តិធម៌, ចំណងជើង ជាអង្គ្លេស Prisoners , Long Beach ផ្នែកកសិណនៃកាលសោកនាដកម្ម សតវត្សទី២០, ១៩៩៩, ៤៣ទំព័រ+ ខ្សែអាត់NK 61835 ( រឿង ល្ខោន ជាភាសាខ្មែរលាយអង្គ្លេស) ។ លោក**នួនកន** អតីតសិស្សលោក**ហង្ស ធុនហាក់** (១៩២៦-៧៥) ជាអតីតសាស្ត្រាចារ្យវិចិត្រសិល្បៈ និងអតីតនាយករដ្ឋមន្ត្រី (១៩៧២-៧៣)។ លោក បានសិក្សាក្នុងជំនាន់ជាមួយឯ.ឧ**ឆេងផុន** និងឯ.ឧ**ហង្សជួន** ទាំងពីរនាក់ សុទ្ធតែជាអតីតរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៃរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ហើយសព្វថ្ងៃ នេះ មាន តួនាទីសំខាន់ៗទៀត ។

(៙២៨) **ប៉ែនសេដ្ឋារិន** ក្រោមមេឃខៀវនៃអង្គរវត្ត ប្រលោមលោក តូក្យូ១៩៩៩ ,២០៥ទំព័រ ។

(៙២៩) **នួនកន** << ល្បង សិក្សា រឿង ផ្កា ស្រពោន >> , Cambodian Studies, Edited by Yasuyuki SAMAMOTA & Makoto MINEGISHI , n° 2, 1999, p.27-33 ។ សព្វថ្ងៃ មានអ្នកស្រាវជ្រាវ ជំនាន់ក្រោយ មានចំណេះដឹង យ៉ាងច្បាស់លាស់ ផ្នែកភាសាខ្មែរ ដូចជា**តូម៉ូកូ អូកាដា** (Tomoko OKADA ) និង**ហ៊ីរ៉ូមី អ៊ុយេដា** (Hiromi UEDA ) ជាដើមនេះ ហើយដែលជាសេចក្តីសង្ឃឹមថា ខេមរវិទ្យានឹងដុះដាលនៅប្រទេសជប៉ុននៅថ្ងៃមុខ។

(៙៣០) សមាគមនេះកើតឡើងនៅឆ្នាំ១៩៣៨ ស្របតាមច្បាប់បារាំង១៩០១ ។

(៙៣១) ទស្សនាវដ្តី សិក្សាខ្មែរ បង្កើតជាដំបូងដោយបណ្ឌិត **ឃីងហុកឌី** ជាចាងហ្វាងដឹកនាំពីឆ្នាំ១៩៨០ ដល់ ១៩៨៣។

(៙៣២) អ្នកស្រី**ស៊ុយហឿង** វាសនានៃនាងណាត្រី ភ្នំពេញ មជ្ឈមណ្ឌល ឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ ១៩៩៩, ៨៥ ទំព័រ ។ ចំពោះអ្នកនិពន្ធរូបនេះ សូមអានKHING Hoc Dy , Ecrivains et expressions littéraires du Cambodge au XXème siècle , Paris ,1993, p.81-85.

(៙៣៣) កើតនៅថ្ងៃ០៧/០២/១៩៥៩ បានសិក្សារហូតដល់ថ្នាក់ទី១ នៅសម័យមុនឆ្នាំ១៩៧៥ ។ ឪពុកឈ្មោះ **ម៉ៅសោម** ជាសាស្ត្រាចារ្យក្នុងសម័យ សង្គមរាស្ត្រនិយម ហើយ បានស្លាប់ នៅ សម័យ **ប៉ុលពត** ។ អ្នកស្រី ផ្តើមសរសេរប្រលោមលោកចាប់តាំងពីឆ្នាំ១៩៨៣ មកតែបានទទួលការបោះពុម្ពផ្សាយគឺចាប់តាំងពីឆ្នាំ១៩៩០ នូវប្រលោមលោកទី១ មានចំណងជើងថា*<<ខ្សែ ក បន្តោងឥដ្ឋ >>*។ បន្ទាប់មកអ្នកស្រីបានសរសេររឿងសំរាប់ថតខ្សែភាពយន្តផ្សាយក្នុងទូរទស្សន៍ និងថតខ្សែភាពយន្តវិដេអូ គឺជាអ្នកនិពន្ធនារីម្នាក់ ដែលមានលទ្ធភាព អាចរស់ បាន នឹង សំណេរ ដោយទទួលកំរៃ ប្រហែល២០០ ដុល្លាអាមេរិក ក្នុង១ខែ ។ (តាមសេចក្តីសម្ភាសន៍ខែសីហា ឆ្នាំ១៩៩៦ នៅស្នាក់ការសមាគមអ្នកនិពន្ធខ្មែរ) ។